សម្រាប់ការចេញផ្សាយភ្លាមៗ

# របាយការណ៍ថ្មី រំលេចពីផលប៉ះពាល់នៃសកម្មភាពរបស់មនុស្ស និង ផ្នែកបរិស្ថាន ក្នុងអាងទន្លេមេគង្គក្រោម

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១** – របាយការណ៍ចំនួនពីរ ដែលចេញផ្សាយដោយគណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) នាថ្ងៃនេះ បង្ហាញថាការនេសាទ នៅតែជារបរចិញ្ចឹមជីវិតដ៏សំខាន់ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ក៏ប៉ុន្តែ ការនេសាទហួសកម្រិត និងការខូចខាតទីជម្រកបណ្តាលមកពីកំណើនប្រជាជនយ៉ាងសន្ធឹកសន្ធាប់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ កំពុងដាក់សម្ពាធយ៉ាងខ្លាំងលើដលផលអាងទន្លេមេគង្គក្រោម ស្របពេលដែលបម្រែបម្រួលនៃប្រព័ន្ធអេកូឡូស៊ីក្នុងអាងនេះ កំពុងជះឥទ្ធិពលលើស្ថានភាពសង្គម។

របាយការណ៍ចំនួនពីរក្រោមចំណងជើង “ស្ថានភាព និងនិន្នាការនៃភាពសម្បូរបែប និងភាពចម្រុះនៃមច្ឆាក្នុងអាងទន្លេមេគង្គក្រោម ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៨” (ហៅកាត់ថា FADM) និង “ការតាមដានផលប៉ះពាល់សង្គម និងការវាយតម្លៃភាពងាយរងគ្រោះឆ្នាំ២០១៨” (ហៅកាត់ថា SIMVA) បានរកឃើញថា ក្រុមគ្រួសារនៅតែបន្តពឹងអាស្រ័យលើធនធានទឹក ដែលកំពុងរងសម្ពាធកាន់តែខ្លាំងឡើង។

បណ្ឌិត អាន ពេជ្រហត្ថដា នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC បានមានប្រសាសន៍ថា “ការសិក្សាស្រាវជ្រាវទាំងនេះ រំលេចបន្ថែមពីសារៈសំខាន់នៃការអភិវឌ្ឍប្រកបដោយទំនួលខុសត្រូវ ផលប្រយោជន៍ថ្នាក់ជាតិ និងតំបន់ដែលមានតុល្យភាព និងកិច្ចសហប្រតិបត្តិការតំបន់កាន់តែរឹងមាំបន្ថែមទៀត ដើម្បីរក្សាការពារធនធានទឹក និងធនធានពាក់ព័ន្ធនៃទន្លេមេគង្គ”។

របាយការណ៍ទាំងពីរនេះ ផ្តល់អនុសាសន៍ឲ្យមានការគាំពារដល់ស្តុកបរិមាណត្រី ដើម្បីធានាឲ្យមានការផ្គត់ផ្គង់ស្បៀងសម្រាប់ប្រជាជនរាប់លានអ្នក ដែលកំពុងរស់នៅតាមអាងទន្លេមេគង្គក្រោម និងរក្សាការពារការធ្លាក់ចុះបន្ថែមទៀតនៃប្រាក់ចំណូលរបស់ក្រុមគ្រួសារ។ បើយោងតាម SIMVA ឆ្នាំ២០១៨ ក្នុងចំណោមក្រុមគ្រួសារចំនួន២.៨០០ មានគ្រួសារដែលស្ទង់មតិ ៣៥% បានលើកឡើងថា ប្រាក់ចំណូលរបស់ពួកគេមានកម្រិតទាបជាងមុន ៣២% ថាស្ថានភាពចំណូលនៅតែដដែល មានតែ ២៦% ប៉ុណ្ណោះដែលថាប្រាក់ចំណូលបានកើនឡើងបន្តិចបន្តួច ខណៈដែល ៦% ទៀតបញ្ជាក់ថា វាបានកើនឡើងគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងឆ្នាំ២០១៣។

ការផ្លាស់ប្តូរអវិជ្ជមានក្នុងធនធានទឹក រួមមានកសិកម្ម វារីវប្បកម្ម មច្ឆា និងសត្វ និងរុក្ខជាតិក្នុងទឹកផ្សេងទៀត កំពុងជះឥទ្ធិពលលើប្រាក់ចំណូល ដោយ២២% នៃក្រុមគ្រួសារ បានបញ្ជាក់ថា ពួកគេរងផលប៉ះពាល់ពីបញ្ហានេះ។

ប៉ុន្តែ ការចិញ្ចឹមជីវិតមិនពាក់ព័ន្ធធនធានទឹកដទៃទៀត រួមទាំងការងារ ឬមុខជំនួញ ឬ ពាណិជ្ជកម្មដែលមានប្រាក់ចំណេញ ដើរតួនាទីរឹតតែសំខាន់ និងអាចកាត់បន្ថយភាពងាយរងគ្រោះលើបម្រែបម្រួលនានាក្នុងធនធានទឹកទន្លេមេគង្គ។ របាយការណ៍ទាំងពីរនេះ លើកឡើងថា វានៅមានវិសាលភាពធំគួរឲ្យកត់សម្គាល់សម្រាប់ការធ្វើឲ្យប្រសើរឡើងវិញ ដែលរដ្ឋាភិបាលអាចរៀបចំចេញជាគោលនយោបាយ

ប្រសិនបើសហគមន៍ត្រូវបានការពារពីភាពងាយរងគ្រោះដោយទឹក និងភាពងាយរងគ្រោះពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

របាយការណ៍ FADM ដែលមានកម្រាស់១៣៨ ទំព័រ គឺជាការសិក្សាស្រាវជ្រាវកម្រិតធំដំបូងបង្អស់ដែល ផ្តោតទាំងលើការផ្លាស់ប្តូរបែបទីកន្លែង (spatial) និង ពេលវេលា (temporal) នៃភាពសម្បូរបែប និងភាពចម្រុះនៃមច្ឆា ក្នុងអាងទន្លេមេគង្គក្រោម ដោយប្រើប្រាស់នូវទិន្នន័យតាមដានការនេសាទរយៈពេលវែងរបស់ MRC។ ការសិក្សានេះ បានបង្ហាញថា ការរំខានពិតជាមានលើសហគមន៍នេសាទ ស្ទើរតែគ្រប់តំបន់នៃអាងទន្លេមេគង្គក្រោម។ បរិមាណនេសាទបានធ្លាក់ចុះ តាមស្ថានីយស្ទង់មតិចំនួន២ ក្នុងចំណោម៤ នៅប្រទេសឡាវ និងស្ថានីយ៣ ក្នុងចំណោម៥ នៅវៀតណាម។

ជាផ្នែកមួយនៃអនុសាសន៍កាន់តែទូលំទូលាយ ការសិក្សានេះ ជំរុញឲ្យរដ្ឋាភិបាលនៃប្រទេសជាសមាជិកទាំងបួន ពង្រឹងបទប្បញ្ញត្តិថ្នាក់ជាតិ និងអនុវត្តរួមគ្នានូវយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ជលផលសម្រាប់អាងទន្លេមេគង្គទាំងមូលដែលបានអនុម័ត ដើម្បីស្តារឡើងវិញនូវសហគមន៍នេសាទដែលរងសម្ពាធ។ ការសិក្សានេះ ក៏បានស្នើបន្ថែមទៀតឲ្យមានផែនការគ្រប់គ្រងទន្លេបែបចម្រុះនានា ដើម្បីដោះស្រាយរាល់ហានិភ័យពីការអភិវឌ្ឍទំនប់វារីអគ្គិសនីដែលកំពុងកើនឡើង។

ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៨ ការតាមដានត្រូវបានអនុវត្តរៀងរាល់ថ្ងៃ ដោយមន្ត្រីជំនាញផ្នែកជលផល នៅតាមស្ថានីយចំនួន៣៨ តាមទន្លេមេនៃទន្លេមេគង្គ និងដៃទន្លេសំខាន់ៗ។ ក៏ប៉ុន្តែ ដោយសារកត្តាកង្វះទិន្នន័យ មានតែទីតាំងចំនួន២៥ ប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ក្នុងនោះ ស្ថានីយចំនួន១១ ស្ថិតក្នុងប្រទេសកម្ពុជា ៤ នៅប្រទេសឡាវ និង៥ នៅប្រទេសថៃ និងវៀតណាម។

របាយការណ៍ SIMVA ដែលមានកម្រាស់១៦៨ ទំព័រ បានប្រមូលនូវព័ត៌មាន និងទិន្នន័យថ្មីៗ ដែលផ្តល់នូវទស្សនៈវិស័យផ្សេងៗលើស្ថានភាពសង្គម ភាពងាយរងគ្រោះ និងសុខភាពសហគមន៍តាមទន្លេមេនៃទន្លេមេគង្គ។ ការកើនឡើងនៃគ្រោះទឹកជំនន់ ដែលបង្កដោយការប្រែប្រួលអាកាសធាតុ និងកត្តាផ្សេងទៀត រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹក គឺជារបបគំហើញមួយក្នុងចំណោមលទ្ធផលសិក្សាគួរឲ្យកត់សម្គាល់ដទៃទៀតក្នុងការសិក្សាស្រាវជ្រាវនេះ។

ក្នុងចន្លោះឆ្នាំ២០១៥ - ២០១៨ ប្រមាណ៦២% នៃភូមិគំរូស្រាវជ្រាវ បានជួបប្រទះនូវការបាត់បង់ និងខូចខាតពីគ្រោះទឹកជំនន់។ ប្រទេសថៃមានសមាមាត្រខ្ពស់បំផុត នៅកម្រិត ៨០% ខណៈដែលវៀតណាមទាបបំផុត នៅកម្រិត៤២%។ ២៥% នៃភូមិទាំងនេះ បានលើកឡើងថា ផលប៉ះពាល់នៃគ្រោះទឹកជំនន់កាន់តែធ្ងន់ធ្ងរខ្លាំងឡើង ហើយ២៥% ទៀតបានរាយការណ៍ថា ផលប៉ះពាល់ទាំងនេះ មានស្ថានភាពអាក្រក់បំផុតក្នុងរយៈពេល១២ ខែចុងក្រោយ បើធៀបទៅនឹងឆ្នាំមុនៗ។ បើប្រៀបធៀបទៅនឹងការស្ទង់មតិឆ្នាំ២០១៤ ការបាត់បង់ និងខូចខាតពីគ្រោះមហន្តរាយបង្កដោយអាកាសធាតុធំៗ ជាពិសេសគ្រោះទឹកជំនន់ បានកើនឡើងគួរឲ្យកត់សម្គាល់។

ការស្ទង់មតិ SIMVA ឆ្នាំ២០១៨ នេះ គឺជាការសិក្សាស្រាវជ្រាវលើកទីបី និងត្រូវបានរៀបចំនៅតាមទីតាំងសិក្សាដដែល និងប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវដូចការស្ទង់មតិឆ្នាំ២០១៤ ដែរ។

ក្នុងចំណោមរបបគំហើញផ្សេងទៀត ការស្ទង់មតិ SIMVA ឆ្នាំ២០១៨ បង្ហាញថា ភាគរយនៃក្រុមគ្រួសារចូលរួមក្នុងសកម្មភាពនេសាទ បានធ្លាក់ចុះនៅទូទាំងតំបន់ទាំងមូល ពី៥០% ក្នុងឆ្នាំ២០១៤ មក

ប្រមាណ ៣៧% នៅឆ្នាំ២០១៨។ ហេតុការណ៍នេះ មួយផ្នែកបណ្តាលមកពីការកាត់បន្ថយបរិមាណនេសាទត្រី និងមួយផ្នែកទៀត ដោយសារកំណើនក្នុងកាលានុវត្តន៍សេដ្ឋកិច្ចដទៃទៀត និងភាពចម្រុះនៃការចិញ្ចឹមជីវិត។

វិសមភាពយេនឌ័រ ក៏ជាកត្តាចំបងមួយ ដែលជួយបង្កើនភាពងាយរងគ្រោះសង្គមផងដែរ។ តួនាទីយេនឌ័រតាមប្រពៃណី កំពុងរីករាលដាលតាមតំបន់ជាច្រើននៃច្រកអាងទន្លេមេគង្គក្រោម ដោយមានភាពខុសគ្នាខ្លាំងក្នុងការងារ និងប្រាក់កំរៃរវាងស្រ្តី និងបុរស។ ក្រុមគ្រួសារដឹកនាំដោយស្រ្តី ត្រូវរងគ្រោះជាងគេ ដោយសារពួកគេក៏ជាក្រុមគ្រួសារទោលផងដែរ។ ការស្ទង់មតិនេះ បានរកឃើញថា ១៩% នៃក្រុមគ្រួសារត្រូវបានដឹកនាំដោយស្រ្តី និង៨១% ដោយបុរស។ ប្រទេសឡាវ និងវៀតណាម មានអត្រាទាបបំផុតនៃក្រុមគ្រួសារដឹកនាំដោយស្រ្តី ពោលគឺត្រឹមតែ ១៣% ស្របពេលដែលថៃ មានកម្រិតខ្ពស់បំផុត គឺ២៧%។

ក្រៅពីគម្រោងផ្តួចផ្តើមស្រាវជ្រាវ FDMA និង SIMVA លំហាត់តាមដានសង្គម-សេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត ដែលបានរៀបចំដោយ MRC ក្រោមកិច្ចសហការជាមួយនឹងប្រទេសជាសមាជិក បានដាក់បញ្ចូលនូវរបាយការណ៍ស្តីពីស្ថានភាពអាងឆ្នាំ២០១៨ ដែលជាការស្រាវជ្រាវកម្រិតធំលើកដំបូង ដើម្បីប្រមូលនូវព័ត៌មានសង្គម-សេដ្ឋកិច្ចយ៉ាងទូលំទូលាយក្នុងអាងទន្លេមេគង្គ រួមទាំងអាងទន្លេមេគង្គផ្នែកខាងលើផងដែរ។

**-ចប់-**

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុភក្រ្ត មន្ត្រីទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទដៃ៖ +856-20-77779168

###